# សុន្ទរកថា

## ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប. ក្នុងពិធីផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ក្រសួងមហាផ្ទៃ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

- **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ**
- **ឯកឧត្តម លោកជំទាវប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីប្រធានក្រុមប្រឹក្សា អភិបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រីសមាជិក សមាជិកានៃអង្គពិធីទាំងមូល ជាទីមេត្រី!**

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាម គ.ជ.អ.ប. និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធីផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពី **"ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ"** ដ៏មានសារៈសំខាន់នាថ្ងៃនេះ។

ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំក៏សូមសម្តែងនូវការកោតសរសើរដោយស្មោះ និងវាយតម្លៃខ្ពស់ចំពោះការគាំទ្រ និងការចូលរួមយ៉ាងសកម្មរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលជាថ្នាក់ដឹកនាំ និងជាមន្ត្រីនៃក្រសួង ស្ថាប័ននៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាក្នុងការរៀបចំ និងការអនុវត្តកម្មវិធី **កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** ឬហៅម្យ៉ាងទៀតថា **"កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"** ឱ្យមានការរីកចម្រើនទៅមុខ ស្របតាមឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ សំដៅធ្វើឱ្យគុណភាពជីវិតរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរឡើង ដើម្បីឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមគូសបញ្ជាក់ជូនអង្គពិធីមេត្តាជ្រាបថា រាជរដ្ឋាភិបាលនីតិកាល

ទី៧នៃរដ្ឋសភានេះ នៅតែតម្កល់ឆន្ទៈយ៉ាងរឹងមាំក្នុងការបន្តជំរុញ និងពង្រឹងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយបានកំណត់យកកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រួមជាមួយកំណែទម្រង់សំខាន់ៗផ្សេងទៀតជាអាទិ៍ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ **ធ្វើជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។**

ក្នុងន័យនេះ រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដោយមានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ជាសេនាធិការ នឹងបន្តពង្រឹង និងជំរុញការអនុវត្ត **"កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ដល់ឆ្នាំ២០៣០"** ដោយបន្តផ្តោតលើការបែងចែកមុខងារ ការទទួលខុសត្រូវ និងខ្សែគណនេយ្យភាពឱ្យបានកាន់តែច្បាស់លាស់រវាងក្រសួង ស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ។

គ.ជ.អ.ប.នឹងបន្តពង្រឹង គាំទ្រ និងអភិវឌ្ឍន៍ស្ថាប័នរដ្ឋបាលក្រុង ស្រុកឱ្យក្លាយជារដ្ឋបាលមូលដ្ឋានជួរមុខ ជាស្ថាប័នអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការដែលតំណាងឱ្យសម្លេង និងផលប្រយោជន៍របស់ប្រជាជន ជាស្ថាប័ន មានស្វ័យភាព មានសមត្ថភាព មានលទ្ធភាពសមស្រប មានគំនិតផ្តួចផ្តើម និងមានលទ្ធភាពគាំទ្រ សម្របសម្រួល និងសហការជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងការផ្តល់សេវាសាធាណៈជាមូលដ្ឋាននិងចាំបាច់នានាជូនប្រជាជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

ទន្ទឹមគ្នានេះ គ.ជ.អ.ប.នឹងរៀបចំការសិក្សាអំពីជម្រើសសមស្របនានាសម្រាប់បន្តអភិវឌ្ឍស្ថាប័នសាធារណៈនៅថ្នាក់ខេត្តឱ្យក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជា**រដ្ឋបាលតំបន់** ដែលមានតួនាទីភារកិច្ច និងការទទួលខុសត្រូវចម្បងៗពាក់ព័ន្ធនឹង (**ទី១**).ការបំពេញមុខងារជាតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស (**ទី២**).ការសម្របសម្រួល ការគាំទ្របច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលមូលដ្ឋាន (រួមមានរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់) ការត្រួតពិនិត្យនីត្យានុកូលភាព ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋានទាំងនោះ ដើម្បីធានាឱ្យរដ្ឋបាលមូលដ្ឋាននីមួយៗបំពេញមុខងាររបស់ខ្លួនស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវាដែលបានកំណត់ និង(**ទី៣**).ការអនុវត្តមុខងារ ឬគម្រោងក្នុងវិស័យសាធារណៈសំខាន់ៗមួយចំនួនដែលមានលក្ខណៈបច្ចេកទេសខ្ពស់ និងមានវិសាលភាពគ្របដណ្តប់លើភូមិសាស្ត្រទូទាំងខេត្តដែលរដ្ឋបាលក្រុង ស្រុក និងឃុំសង្កាត់ពុំអាចអនុវត្តបាន។

ជាមួយគ្នានេះ ដើម្បីធានាដល់ការដោះស្រាយបញ្ហាប្រឈមដែលបាន និងកំពុងជួបប្រទះក្នុងរាជធានីភ្នំពេញ ដោយសារកំណើនប្រជាជនមករស់នៅ រៀនសូត្រ និងប្រកបការងារក្នុងរាជធានីភ្នំពេញ

ជាអាទិ៍ បញ្ហាសណ្ដាប់ធ្នាប់សាធារណៈ សេវាដឹកជញ្ជូនទីក្រុង ការកកស្ទះចរាចរណ៍ សំណល់រឹងរាវ ការបំពុលបរិស្ថាន ការរីកដុះដាលយ៉ាងលឿននូវទីក្រុងរណបតាមតំបន់ជាយក្រុង។ល។និង។ល។ ដែលបញ្ហាទាំងនេះទាមទារឱ្យមានដំណោះស្រាយជាលក្ខណៈប្រព័ន្ធ និងសម្រាប់រយៈពេលវែង។ ក្នុងន័យនេះ គ.ជ.អ.ប. នឹងរៀបចំឱ្យមានការសិក្សាអំពីជម្រើសសមស្របសម្រាប់រៀបចំរដ្ឋបាលរាជធានីភ្នំពេញឱ្យក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈ**ជារដ្ឋបាលមេត្រូប៉ូលីទែន** (ទីក្រុងធំមានមនុស្សច្រើនកុះករ) ដែលបំពេញតួនាទីជារដ្ឋបាលតំបន់ផង និងជារដ្ឋបាលមូលដ្ឋានផង ព្រមទាំងគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ស្របតាមការកំណត់ក្នុងច្បាប់រៀបចំអង្គការស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ស្របជាមួយនឹងការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលនឹងបន្តផ្ទេរសិទ្ធិអំណាច ការទទួលខុសត្រូវ មុខងារ និងធនធានកាន់តែច្រើនបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវធ្វើឡើងជាដំណាក់កាល មានផែនការច្បាស់លាស់ និងមានការពិគ្រោះយោបល់ទូលំទូលាយ ដើម្បីធានាឱ្យស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានសមត្ថភាព និងលទ្ធភាពក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមនានារបស់ប្រជាជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

ជាការពិតណាស់ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកំណែទម្រង់ដែលមានលក្ខណៈស្មុគស្មាញ និងសាំញ៉ាំ ក៏ប៉ុន្តែជាកំណែទម្រង់**ផ្នែកអភិបាលកិច្ចដែលផ្ដល់ផលប្រយោជន៍ដោយផ្ទាល់ដល់ការលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន**។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភានៅតែមានការតាំងចិត្តយ៉ាងមុតមាំ និងច្បាស់លាស់ក្នុងការបន្តរៀបចំ និងអនុវត្តកំណែទម្រង់នេះឱ្យទទួលបានជោគជ័យសម្រាប់រយៈពេលវែង។ ជាមួយគ្នានេះ យើងក៏ត្រូវទទួលស្គាល់ថា ការអនុវត្តកំណែទម្រង់នេះនាពេលកន្លងមក ទោះបីសម្រេចបាននូវសមិទ្ធផលធំៗជាច្រើនក៏ដោយ ក៏យើងបានជួបនូវបញ្ហាប្រឈមជាច្រើន ដោយសារតែកំណែទម្រង់នេះមានផលប៉ះពាល់ដល់សិទ្ធិអំណាច និងធនធានរបស់ស្ថាប័ន ហើយបញ្ហាប្រឈមដ៏លំបាកបំផុតនោះ គឺការធ្វើឱ្យមានការផ្លាស់ប្ដូរផ្នត់គំនិត និងរបៀបរបបបំពេញការងាររបស់មន្ត្រីឱ្យស្របទៅតាមបែបបទថ្មីនៃកំណែទម្រង់ នោះគឺ**ការប្រកាន់ខ្ជាប់នូវឥរិយាបថជាមន្ត្រីបម្រើសេវាជូនប្រជាជនប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌យ៉ាងពិតប្រាកដ**។

ទោះបីយ៉ាងណាក៏ដោយ ផ្អែកលើគោលការណ៍គន្លឹះនៃអភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយមានការចូលរួមពីប្រជាជន ការធ្វើវិមជ្ឈការត្រូវបានទទួលស្គាល់ថា ជាជម្រើសដ៏សមស្របនិងមានប្រសិទ្ធភាពបំផុតក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ ដែលប្រទេសជាច្រើនលើសកលលោកកំពុងប្រកាន់យក។

ជារួម ការធ្វើវិមជ្ឈការនឹងជួយលើកកម្ពស់ប្រជាធិបតេយ្យនៅមូលដ្ឋាន ពង្រឹងអភិបាលកិច្ចល្អ

ប្រមូលនូវគំនិតផ្តួចផ្តើមដ៏សម្បូរបែបនានា ព្រមទាំងផ្តល់ឱកាសឱ្យមានការចូលរួមពីប្រជាជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ដើម្បីរួមគ្នាធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវា និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដោះស្រាយបញ្ហាប្រឈមនានាបានទាន់ពេលវេលា ចូលរួមចំណែកក្នុងការអភិវឌ្ឍជាតិលើគ្រប់វិស័យ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនយ៉ាងមានប្រសិទ្ធភាព។ ក្នុងន័យនេះ យើងត្រូវតែបន្តខិតខំប្រឹងប្រែងជំនះរាល់ឧបសគ្គទាំងឡាយ ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការចូលរួមអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ឱ្យទទួលបានជោគជ័យតាមការរំពឹងទុក។

### ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ថ្ងៃនេះ គ.ជ.អ.ប. បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពី "ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ" ដោយបានអញ្ជើញអ្នកចូលរួមប្រមាណជាង៦០០នាក់ ជាពិសេស **គឺការចូលរួមពីប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស** ដែលរាជរដ្ឋាភិបាលបានចាត់ទុកថា ជារដ្ឋបាលមូលដ្ឋាននៅកៀកជិតប្រជាពលរដ្ឋ និងមានលក្ខណៈសម្បត្តិសមស្របបំផុតសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំ យុវជន និងកីឡាក្នុងកម្រិតបឋមសិក្សាចុះក្រោម ប្រកបដោយប្រសិទ្ធភាព ស្របតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត កម្មវិធីសិក្សា និងស្តង់ដាសេវាអប់រំដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ក្នុងពេលបើកពិធីនាព្រឹកមិញនេះ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** បានថ្លែងសុន្ទរកថា ដោយបានគូសបញ្ជាក់ជូនអង្គពិធីនូវសារជាគន្លឹះនានាពាក់ព័ន្ធនឹងសារៈសំខាន់នៃការអប់រំ យុវជន និងកីឡា លក្ខខណ្ឌចាំបាច់នានានៃការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ តួនាទី ការទទួលខុសត្រូវ និងខ្សែគណនេយ្យភាពរវាងក្រសួងអប់រំ យុវជននិងកីឡា និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងចំណុចសំខាន់ៗនានាដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរឱ្យទាំងនេះប្រកបដោយប្រសិទ្ធភាព ស្របតាមគោលនយោបាយនិងស្តង់ដាកំណត់។

ក្នុងពិធីនេះដែរ តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានធ្វើបទបង្ហាញយ៉ាងច្បាស់អំពីខ្លឹមសារសំខាន់ៗនៃអនុក្រឹត្យស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងបានគូសបញ្ជាក់ជូនអង្គពិធីនូវកិច្ចការជាអាទិភាពនានាដែលត្រូវបន្តរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងរយៈពេលចំពោះមុខនេះ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចចាប់ផ្តើមអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរឱ្យទាំងនេះឱ្យមានប្រសិទ្ធភាពខ្ពស់**ចាប់ពីខែមករា ឆ្នាំ**

២០២៤នេះតទៅ។

ទោះយ៉ាងនេះក្តី ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមលើកឡើងបន្ថែមអំពីសារៈសំខាន់នៃការងារអប់រំ យុវជន និងកីឡា និងការផ្តល់អាទិភាពដល់វិស័យអប់រំ យុវជន និងកីឡា ដោយរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងបទពិសោធន៍មួយចំនួនពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការក្នុងវិស័យអប់រំ ដែលបាន និងកំពុងអនុវត្តនៅតាមបណ្តាប្រទេសនានា។

ក្នុងបណ្តាប្រទេសនានាលើពិភពលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាបានចាត់ទុកវិស័យអប់រំ គឺជាវិស័យអាទិភាពដ៏មានសារៈសំខាន់បំផុត និងជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍធនធានមនុស្សដែលជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់អភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។ ខ្ញុំសូមលើកឡើងមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងពាក់ព័ន្ធនឹងការងារអប់រំនេះ។ មាត្រា៦៥បានចែងថា *"រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប"* មាត្រា៦៦បានចែងថា *"រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេសដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ និងស្មើគ្នាក្នុងការកសាងជីវិត"* និង មាត្រា៦៨ ចែងថា *"រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ"*។

ក្នុងន័យនេះ រាជរដ្ឋាភិបាលតែងតែផ្តោតការយកចិត្តទុកដាក់ និងផ្តល់អាទិភាពជាចម្បងលើការជំរុញ និងការលើកកម្ពស់ការផ្តល់សេវាអប់រំប្រកបដោយគុណភាព ប្រសិទ្ធភាព បរិយាប័ន្ន និងសមធម៌សង្គម។ ជាក់ស្តែង កម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភាដែលបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកដំបូងកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣កន្លងមកនេះ បានបន្តផ្តោតទៅលើវិស័យជាអាទិភាពចំនួន៥ គឺមនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ដែលក្នុងនោះការអភិវឌ្ឍធនធានមនុស្សគឺជាអាទិភាពទី១ បន្ទាប់មក ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យាគឺជាអាទិភាពបន្តបន្ទាប់តាមលំដាប់ ហើយការពង្រឹងគុណភាពវិស័យអប់រំ យុវជន កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាត្រូវបានកំណត់ជាមុំទី១នៃបញ្ចកោណទី១ពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស។

ក្នុងក្របខណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ វិស័យអប់រំ យុវជន និងកីឡាក៏ត្រូវបានកំណត់ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពដទៃទៀតដែលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានតម្រូវឱ្យមានការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡានេះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាអប់រំ ជាពិសេសសេវាអប់រំកុមារតូច សេវាអប់រំបឋមសិក្សា សេវាអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន ការអប់រំកាយ និង

កីឡានៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្វិតការសម្រេចចិត្ត និងការទទួលខុសត្រូវលើការផ្តល់សេវាអប់រំទាំងនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលជារដ្ឋបាលមូលដ្ឋាននៅកៀកជិតប្រជាជន។

ផ្អែកតាមការសិក្សាស្រាវជ្រាវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. បានបង្ហាញឱ្យឃើញថា ក្នុងទសវត្សថ្មីៗនេះ ប្រទេសជាច្រើនរួមទាំងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍បាន និងកំពុងធ្វើវិមជ្ឈការវិស័យអប់រំ តាមរយៈការប្រគល់ការទទួលខុសត្រូវលើការគ្រប់គ្រងសាលារៀន ការគ្រប់គ្រងថវិកាសម្រាប់ប្រតិបត្តិការសាលារៀន និងការគ្រប់គ្រងគ្រូបង្រៀនទៅឱ្យរដ្ឋបាលមូលដ្ឋាន ការផ្តល់ស្វ័យភាពដល់សាលារៀន និងការផ្តល់សិទ្ធិដល់សហគមន៍ចូលរួមគ្រប់គ្រង និងប្រតិបត្តិការសាលារៀនរដ្ឋដោយអនុលោមទៅតាមគោលនយោបាយ កម្មវិធីអប់រំ និងស្តង់ដារអប់រំរបស់ជាតិ។ ការធ្វើវិមជ្ឈការក្នុងវិស័យអប់រំត្រូវបានអនុវត្តក្នុងទម្រង់ និងក្នុងកម្រិតផ្សេងៗគ្នាពីប្រទេសមួយទៅប្រទេសមួយ។ នៅក្នុងតំបន់យើងនេះ មានប្រទេសមួយចំនួនបាន និងកំពុងធ្វើវិមជ្ឈការការងារអប់រំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរដ្ឋបាលមូលដ្ឋាន ដោយបានធ្វើឱ្យគុណភាពនៃសេវាអប់រំកាន់តែមានភាពល្អប្រសើរជាលំដាប់ ជាអាទិ៍ ប្រទេសសិង្ហបុរី ឥណ្ឌូនេស៊ី វៀតណាម ថៃ និងប្រទេសកូរ៉េខាងត្បូងជាដើម។

ចំពោះប្រទេសកម្ពុជារបស់យើង បើយើងពិនិត្យមើលថយក្រោយនៅមុនឆ្នាំ១៩៩៣ ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម័យរដ្ឋកម្ពុជា មន្ទីរ និងការិយាល័យជំនាញនានារាប់ទាំងមន្ទីរ និងការិយាល័យអប់រំ សាលារៀនគឺជាអង្គភាពដែលស្ថិតនៅក្រោមការដឹកនាំ និងការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត ក្រុង និងស្រុក ហើយត្រូវអនុវត្តស្របតាមគោលនយោបាយ និងស្តង់ដាដែលក្រសួងទទួលបន្ទុកអប់រំនៅថ្នាក់ជាតិ។ ប៉ុន្តែក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលត្រូវរៀបចំឡើងវិញដែលក្នុងនោះមុខងារ សិទ្ធិអំណាច និងធនធានដែលបានផ្តល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំគ្រប់គ្រងដោយក្រសួង ស្ថាប័នថ្នាក់ជាតិតាមប្រព័ន្ធមជ្ឈការឡើងវិញ ហើយបច្ចុប្បន្ននេះ យើងបាន និងកំពុងផ្ទេរសិទ្ធិ អំណាច មុខងារ និងធនធានជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យមានការចូលរួមទទួលខុសត្រូវ និងភាពម្ចាស់ការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងចាត់ចែង ផ្តល់សេវាសាធារណៈ និងការដោះស្រាយបញ្ហាប្រឈមនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជារួម កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ត្រូវបានរៀបចំ និងអនុវត្តដោយផ្អែកលើបរិបទ និងស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច នយោបាយ និងវប្បធម៌ជាក់ស្តែងរបស់កម្ពុជា ដោយប្រកាន់ខ្ជាប់នូវវិធីសាស្ត្រអនុវត្តផង រៀនសូត្រផង និងកែលម្អជាបណ្តើរៗផង ផ្អែកលើមេរៀន និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែង ដើម្បីធានាដល់ការជំរុញកំណែទម្រង់នេះឱ្យមានការវិវឌ្ឍទៅមុខជាជំហានៗ និងតាមដំណាក់កាលនីមួយៗប្រកបដោយជោគជ័យ ព្រមទាំងអាចបង្ការ ទប់ស្កាត់ និងដោះស្រាយបញ្ហាប្រឈម និងហានិភ័យផ្នែកនយោបាយនានាដែលអាចកើតឡើងជាយថាហេតុបានទាន់ពេលវេលា។

ជាក់ស្តែង ការផ្ទេរមុខងារវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ យើងបានអនុវត្តដោយប្រយ័ត្នប្រយែងដោយបានចាប់ផ្តើមពីការផ្ទេរមុខងារចំនួន០៦ក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងឆ្នាំ២០២០ ទៅតាម**ទិដ្ឋភាព២ផ្សេងគ្នា គឺ៖**

**ទិដ្ឋភាពទី១៖** គឺការផ្ទេរមុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៨ក្នុងខេត្តបាត់ដំបង តាមរយៈ**ការប្រគល់ (វិមជ្ឈការ)នូវមុខងារចំនួន៣** រួមមាន មុខងារគ្រប់គ្រងការអប់រំកុមារតូច មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា និងមុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ និងតាមរយៈ**ការធ្វើប្រតិភូកម្ម (វិសហមជ្ឈការ)នូវមុខងារចំនួន៣** រួមមាន មុខងារគាំទ្រការងាររដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សា មុខងារគាំទ្រការងារអភិវឌ្ឍន៍យុវជន និងមុខងារគាំទ្រការងារអប់រំកាយ និងកីឡា។

**ទិដ្ឋភាពទី២៖** គឺការផ្ទេរមុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌផ្សេងទៀតក្រៅពីខេត្តបាត់ដំបង ដោយផ្ទេរតាមរយៈ**ការធ្វើប្រតិភូកម្ម(វិសហមជ្ឈការ)**នូវមុខងារអប់រំទាំង៦ខាងលើនេះ។

ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាតាម**ទិដ្ឋភាពទី១** ទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៨ក្នុងខេត្តបាត់ដំបង គឺមានគោលបំណងអនុវត្តសាកល្បងជាជំហានដំបូង ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការសម្រេចចិត្តខាងនយោបាយ ក្នុងការពង្រីកការធ្វើវិមជ្ឈការមុខងារអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌផ្សេងទៀតនៅទូទាំងប្រទេស។

បន្ទាប់ពីការអនុវត្តក្នុងរយៈពេលជាង៣ឆ្នាំកន្លងមកនេះ គ.ជ.អ.ប.បានដឹកនាំសម្របសម្រួលក្រុមការងារអន្តរក្រសួងមួយដែលមានសមាសភាពមកពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសិក្សាវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនោះ។ ផ្អែកតាមលទ្ធផលនៃការសិក្សាវាយតម្លៃ បានបង្ហាញឱ្យឃើញថា ការផ្ទេរមុខងារអប់រំ យុវជន និងកីឡា**តាមបែបវិមជ្ឈការ**ទៅឱ្យរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបងបានទទួលលទ្ធផលជាវិជ្ជមាន និងមានលក្ខណៈល្អប្រសើរជាងការផ្ទេរមុខងារអប់រំ យុវជន និងកីឡាតាមបែប**វិសហមជ្ឈការ**ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌផ្សេងទៀត។ ផ្អែកលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានសម្រេចពង្រីកការប្រគល់មុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាតាមទិដ្ឋភាពដូចដែលបានអនុវត្តនៅតាមរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងឱ្យទៅអនុវត្តនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស តាមរយៈការដាក់ចេញនូវអនុក្រឹត្យលេខ២១៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី "ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ" ដែលយើងកំពុងរៀបចំពិធីផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនាថ្ងៃនេះ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ខ្ញុំសូមគូសបញ្ជាក់ឡើងវិញថា ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាល

ក្រុង ស្រុក ខណ្ឌ តាមរយៈអនុក្រឹត្យលេខ២១៣នេះ គឺជាការបែងចែកឡើងវិញឱ្យបានច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវរវាងក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំដែលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របជាមួយនឹងគោលបំណងនៃកំណែទម្រង់ក្នុងវិស័យអប់រំដែលបាន និងកំពុងអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡាផងដែរ។

ទោះបីជាមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទាំងនេះត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ដោយ ក៏ប៉ុន្តែក្រសួងអប់រំ យុវជន និងកីឡានៅតែជាស្ថាប័នដែលត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភា លើគុណភាពសេវាអប់រំដែលបានផ្ទេរទាំងនេះ។ ក្រសួងអប់រំ យុវជន និងកីឡានៅតែមានតួនាទីសំខាន់ក្នុងការរៀបចំគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ ការសិក្សាស្រាវជ្រាវ កម្មវិធីសិក្សាជាតិ និយាមនិងស្តង់ដាអប្បបរមា ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូ ការគាំទ្របច្ចេកទេស ការតាមដានត្រួតពិនិត្យ និងវាយតម្លៃពាក់ព័ន្ធទៅនឹងមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺជាការផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចូលរួមទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាអប់រំជូនប្រជាជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីលើកកម្ពស់គណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។

ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានគណនេយ្យភាពចំពោះក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនលើលទ្ធផលនៃការដឹកនាំ ការគ្រប់គ្រង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យទាំងនោះ ដោយត្រូវធានាថាការអនុវត្តមុខងារទាំងនេះត្រូវតែស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ កម្មវិធីសិក្សាជាតិ និយាម និងស្តង់ដាដែលបានកំណត់។ ក្នុងក្របខណ្ឌនៃការផ្ទេរមុខងារអប់រំនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌមានតួនាទីសំខាន់ក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរទាំងនោះដោយផ្ទាល់ រួមមានដូចជា ការរៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ ការគ្រប់គ្រងបុគ្គលិកអប់រំនិងគ្រូបង្រៀន ការធានារក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ បរិស្ថានល្អនៅតាមសាលារៀន ការគ្រប់គ្រង ការថែទាំ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងឧបករណ៍សម្ភារនានាពាក់ព័ន្ធនឹងសាលារៀន ការសហការ និងការកៀរគរការចូលរួមគាំទ្រពីសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដើម្បីធានាឱ្យសម្រេចបានយ៉ាងហោចតាមនិយាម និងស្តង់ដាកម្រិតអប្បបរមានៃការគ្រប់គ្រងមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរឱ្យ។

អនុក្រឹត្យស្តីពី "ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ" នេះ បានតម្រូវឱ្យ គ.ជ.អ.ប. ត្រូវដឹកនាំសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាល

ក្រុង ស្រុក ខណ្ឌ រៀបចំផ្ទេររចនាសម្ព័ន្ធ បុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងរៀបចំសេចក្តីណែនាំបច្ចេកទេសស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងត្រូវរៀបចំការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពដល់ថ្នាក់ដឹកនាំ មន្ត្រីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានាឱ្យបានរួចរាល់នៅមុនដំណាច់ឆ្នាំ ២០២៣ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗអាចចាប់ផ្តើមគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរឱ្យទាំងនេះចាប់ពីខែមករា ឆ្នាំ២០២៤តទៅ។

អាស្រ័យហេតុនេះ ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមស្នើឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ផ្តោតការយកចិត្តទុកដាក់ក្នុងការរៀបចំ និងអនុវត្តសកម្មភាពជាអាទិភាពមួយចំនួនដូចខាងក្រោម៖

**ទីមួយ៖ ស្នើក្រសួងអប់រំ យុវជន និងកីឡា**បន្តសហការជាមួយលេខាធិការដ្ឋានគ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំបញ្ចប់សេចក្តីណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យបានរួចរាល់ ដើម្បីឈានទៅរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌនាចុងឆ្នាំ២០២៣នេះ។ ទន្ទឹមគ្នានេះ ស្នើបន្តសហការជាមួយក្រសួងមុខងារសាធារណៈ ក្នុងការរៀបចំ និងដាក់ចេញប្រកាសផ្ទេរបុគ្គលិកអប់រំដែលកំពុងបម្រើការងារនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ស្របតាមបែបបទនិងនីតិវិធីជាធរមាន ឱ្យបានរួចរាល់យ៉ាងយូរត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០២៣នេះ។ ទន្ទឹមនេះ ផ្អែកតាមការណែនាំរបស់**សម្តេចធិបតី នាយករដ្ឋមន្ត្រី**ក្នុងកិច្ចប្រជុំជាមួយអភិបាលរាជធានី ខេត្ត កាលពីថ្ងៃទី ១៣ ខែកញ្ញាកន្លងទៅនេះ ខ្ញុំសូមស្នើលេខាធិការដ្ឋាន គ.ជ.អ.ប. ធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ធ្វើការពិនិត្យឡើងវិញអំពីគោលការណ៍ បែបបទ នីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងនាយកសាលា ដើម្បីធានាឱ្យមានតម្លាភាព គណនេយ្យភាព និងធានាបានការគ្រប់គ្រង ការចាត់ចែងមុខងារអប់រំស្របតាមស្តង់ដារដែលបានកំណត់។ ការពិនិត្យឡើងវិញនេះមិនមានន័យថាថ្នាក់ជាតិដកត្រឡប់មកវិញនូវមុខងារនេះពីរដ្ឋបាលថ្នាក់ក្រោមជាតិនោះឡើយ។

**ទីពីរ៖ ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**បន្តសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការរៀបចំ និងអនុវត្តកិច្ចការ ចាំបាច់នានារួមមាន (១).ការកំណត់ទំហំធនធានហិរញ្ញវត្ថុ និងរៀបចំការផ្ទេរធនធានហិរញ្ញវត្ថុទាំងនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យបានទាន់ពេលវេលានៃការចាប់ផ្តើមអនុវត្តនាដើមឆ្នាំ២០២៤ (២).ការរៀបចំប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងលក្ខខណ្ឌផ្សេងៗសម្រាប់ការផ្ទេរ និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះ និង(៣).ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ និងការផ្ទេរទ្រព្យសម្បត្តិ

ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងការរៀបចំ និងដាក់ចេញនូវគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិដែលបានផ្ទេរទាំងនោះ។

**ទីបី៖ ស្នើក្រសួងមុខងារសាធារណៈ**សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋានគ.ជ.អ.ប. រៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីគោលការណ៍ បែបបទ និងនីតិវិធីគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យបានរួចរាល់នៅចុងឆ្នាំ២០២៣។

**ទីបួន៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋានគ.ជ.អ.ប.** ត្រូវសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំយន្តការគាំទ្របច្ចេកទេស ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យមានប្រសិទ្ធភាពខ្ពស់ ស្របតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវាអប់រំដែលបានកំណត់។

**ទីប្រាំ៖ រដ្ឋបាលរាជធានី ខេត្ត**ត្រូវរៀបចំយន្តការគាំទ្រដោយមានការចូលរួមពីមន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរមុខងារសាធារណៈ និងមន្ទីរអង្គភាពពាក់ព័ន្ធក្នុងការផ្តល់ការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាដល់ការសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈមនានាឱ្យបានទាន់ពេលវេលាពាក់ព័ន្ធនឹងការអនុវត្តមុខងារអប់រំ យុវជន និងកីឡា។

**ទីប្រាំមួយ៖ ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌទាំងអស់** ត្រូវផ្តោតការយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងភាពម្ចាស់ការលើការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មឱ្យទាំងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមគោលនយោបាយ គោលការណ៍ នីតិវិធី និងស្តង់ដាដែលបានកំណត់ និងត្រូវរៀបចំផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីមុខងារ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរឱ្យទាំងនោះឱ្យបានជ្រួតជ្រាបជូនដល់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ គណៈកម្មការទ្រទ្រង់សាលា ក្រុមប្រឹក្សាឃុំ សង្កាត់ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។

ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាម គ.ជ.អ.ប. និងក្នុងនាមខ្ញុំជាប្រជាពលរដ្ឋមួយរូប ខ្ញុំចង់ឃើញគុណភាពនៃសេវាអប់រំនៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈទាំងអស់ដែលត្រូវបានប្រគល់ទៅឱ្យស្ថិតក្រោមការគ្រប់គ្រង ការចាត់ចែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានការកែលម្អឱ្យមានលក្ខណៈកាន់តែល្អប្រសើរឡើងទាំងប្រសិទ្ធភាពនៃការគ្រប់គ្រងទាំងគុណភាពនៃសេវាអប់រំ ដោយទទួលបានការពេញចិត្តពីសាធារណជន ព្រមទាំងធ្វើជាគំរូល្អ និងនាំមុខគ្រឹះស្ថានសិក្សាឯកជននានា។

គ.ជ.អ.ប. នឹងដឹកនាំសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងពិនិត្យ និងវាយតម្លៃលើការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំទាំង

នេះទាំងទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រង និងគុណភាពនៃការផ្តល់សេវាអប់រំ ដើម្បីមានវិធានការចាំបាច់នានា ក្នុងការគាំទ្រ ការលើកទឹកចិត្ត ការណែនាំ និងការធ្វើអន្តរាគមន៍ ដើម្បីធានាដល់ប្រសិទ្ធភាព គុណភាព និងនិរន្តរភាពនៃសេវាអប់រំ ស្របតាមគោលនយោបាយ គោលការណ៍ និងស្តង់ដាអប់រំ។

មុននឹងបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាល គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលជាថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួង ស្ថាប័ន និងអង្គភាពនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលតែងតែបានគាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាពិសេសក្នុងកិច្ចដំណើរការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដូចបានប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនាថ្ងៃនេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ**អង្គការ GIZ** ដែលតែងតែបានផ្តល់កិច្ចសហការក្នុងភាពជាដៃគូ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងធនធានដល់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសការគាំទ្រដល់កិច្ចដំណើរការសិក្សាវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនាពេលកន្លងមក។

ខ្ញុំក៏សូមស្នើឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់បន្តការគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងរួមរបស់យើង គឺការពង្រឹងគុណភាពសេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**